ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**<u>តាមនាមប្រជារាស្ត្រខ្មែរ</u>**

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧៣/១០-០១-០៧

**<u>សាលដីកា</u>**
លេខ ១១៩ "ង"ចុះចុះ
ទី ២១-០៧-២០០៩

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី ២១-០៧-០៩ ដែលមានសមាសភាពដូចតទៅៈ

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌដែលមានលេខ ៧៣ ចុះថ្ងៃទី ១០-០១-២០១២ រវាង ៖

-<u>ជនជាប់ចោទឈ្មោះ</u>

១-[redacted] រិន ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីកន្លែងកំណើត និងសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] លន់"ស" ម្តាយ [redacted] អាន"ស" ប្រពន្ធឈ្មោះ [redacted] យ៉ុន មានកូនចំនួន០២នាក់ ទោសពីមុនគ្មាន"(ឃុំខ្លួន) (ប្តឹងឧទ្ធរណ៍)។ មានមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] សុខា។ (ប្តឹងឧទ្ធរណ៍)

២-[redacted] **ម៉ោង** ហៅ **ខេមា** ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ។ (មិនប្តឹងឧទ្ធរណ៍)

៣-[redacted] ពេជ ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ..។ (មិនប្តឹងឧទ្ធរណ៍)

**<u>ត្រូវជាប់ចោទពីបទ</u>** ៖ ប្លន់ ប្រដាប់អាវុធ

ប្រព្រឹត្តនៅភូមិគកធំ ឃុំព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី ០៥-០៤-២០០៦ តាមមាត្រា ០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ មានទីលំនៅ [redacted]។



Scanned with CamScanner

## ឯរឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ០៥-០៤-២០០៦ ម៉ោងប្រហែល ៨.៤៥ ព្រឹក ជនរងគ្រោះឈ្មោះ [redacted] ចេង បានជិះម៉ូតូចន្លោះចំណុចភូមិគគធំ និងភូមិព្រៃស្រឡិត បានជួបពួកចោរជិះម៉ូតូមួយគ្រឿងម៉ាកសង់កូរ៉េ ពណ៌ក្រហម ឌុបគ្នា០៣នាក់ ជិះទទឹមម៉ូតូជនរងគ្រោះចាប់ដៃជនរងគ្រោះអូសចេញពីលើម៉ូតូ រួចធ្វើសកម្មភាពដកអាវុធខ្លីមិនស្គាល់ម៉ាកភ្ជង់ជនរងគ្រោះយកខ្សែករ ទម្ងន់០៦ជី និងម៉ូតូមួយគ្រឿង គេចខ្លួនបាត់។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៦៥"ខ" ចុះថ្ងៃទី ០៥-១២-២០០៦ របស់សាលាដំបូងខេត្តព្រៃវែង ដែលមានខ្លឹមសារសម្រេចដូចតទៅ៖

១-ផ្តន្ទាទោស៖

ក/-ឈ្មោះ [redacted] រិន ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ"ប្រាំឆ្នាំ" គិតចាប់ពីថ្ងៃផុតកំណត់ទោស ក្នុងសាលក្រមលេខ ៩១"ក"ព្រទ ចុះថ្ងៃទី ២០-១០-២០០៦។

ខ/-ឈ្មោះ [redacted] ពេជ ភេទប្រុស អាយុ៣៩ឆ្នាំ ដាក់ពន្ធនាគារកំណត់០៦ឆ្នាំ"ប្រាំមួយ" គិតពីថ្ងៃចាប់ខ្លួនបាន។

គ/-ឈ្មោះ [redacted] ប៉ោង ហៅ ខែមា ភេទប្រុស អាយុ៣៩ឆ្នាំ ដាក់ពន្ធនាគារកំណត់០៦ "ប្រាំមួយ" គិតពីថ្ងៃចាប់ខ្លួនបាន។

ពីបទៈ ប្លន់ ប្រដាប់អាវុធ ប្រព្រឹត្តនៅភូមិគគធំ ឃុំព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី ០៥-០៤-២០០៦។ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២-បង្គាប់ឱ្យឈ្មោះ [redacted] រិន ,ឈ្មោះ [redacted] ពេជ,ឈ្មោះ [redacted] ប៉ោង ហៅ ខែមា ចេញសំណងថ្លៃម៉ូតូ ថ្លៃខ្សែករ និងជម្ងឺចិត្ត ១០៥០$។ ក្នុងម្នាក់ចំនួន ៣៥០$ ឱ្យទៅឈ្មោះ [redacted] ជាដើមបណ្តឹងរដ្ឋប្បវេណី។ សុំលើសលើកចោល។

-ករណីរឹងរូសពុំព្រមសងត្រូវដាក់គុកបង្ខំរូបកាយទារប្រាក់តាមមាត្រា ០៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយទារប្រាក់ក្នុងរឿងព្រហ្មទណ្ឌ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រិន កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ពេជ និងឈ្មោះ [redacted] ប៉ោង ហៅ ខែមា,ចំពោះមុខមេធាវីការពារឱ្យជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ទុកសិទ្ធិឱ្យប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៥-១២-២០០៦ របស់ឈ្មោះ [redacted] រិន សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៥"ខ" ចុះថ្ងៃទី ០៥-១២-២០០៦ របស់សាលាដំបូងខេត្តព្រៃវែង លើចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញរបាយការណ៍របស់ចៅក្រមសាលាឧទ្ធរណ៍ចុះថ្ងៃទី ២៨-០៥-២០០៩។



Scanned with CamScanner

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ១៤-១២-២០០៧។

**នាពេលសវនាការសាលាឧទ្ធរណ៍**

ចៅក្រមអានរបាយការណ៍រឿង

-ឈ្មោះ [redacted] រិន "អវត្តមាន"

**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា**

-សំអាងហេតុនៃសេចក្តីសម្រេចក្នុងសាលក្រមព្រហ្មទណ្ឌលេខ ៦៥"ខ" ចុះថ្ងៃទី ០៥-១២ ២០០៦ មានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបាន។

-មេធាវី [redacted] សុខា ការពារសិទ្ធិឱ្យឈ្មោះ [redacted] រិន បានធ្វើសេចក្តីសន្និដ្ឋានថា តាមការសិក្សាសំណុំរឿងឃើញថា សាលក្រមរបស់សាលាដំបូងខេត្តព្រៃវែង បានផ្តន្ទាទោសកូនក្តីខ្លួនឈ្មោះ [redacted] រិន ដោយផ្អែកលើកំណត់ហេតុសួរចម្លើយនៅចៅក្រមស៊ើបសួរ និងសមត្ថកិច្ចមានភាពប្រែប្រួល ម្យ៉ាងទៀតឈ្មោះ [redacted] រិន ជាអ្នកភ្លង់ និងឈ្មោះ ពេជ ជាអ្នកជណ្តើមម៉ូតូ រីឯជនរងគ្រោះក៏មិនបានស្គាល់ជនល្មើសច្បាស់ដែរ ដូច្នេះវិមតិសង្ស័យត្រូវបានផលប្រយោជន៍ដល់ជនជាប់ចោទ។ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាពិចារណាដោយក្តីអនុគ្រោះដល់កូនក្តីខ្លួន។

**សភាព្រហ្មទណ្ឌយល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៥-១២-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] រិន ធ្វើឡើងក្នុងកំណត់ច្បាប់ មាត្រា ១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៦០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-លិខិតលេខ ៤៣២ គ.ម/០៩ ចុះថ្ងៃទី ០៧-០៧-២០០៩ របស់ប្រធានគណៈមេធាវីដែលបានចាត់តាំងលោក [redacted] សុខា ធ្វើជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] រិន មានភាពត្រឹមត្រូវតាមច្បាប់។

៣-ដីកាសន្និដ្ឋានស្ថាពរលេខ ៥០៦ ចុះថ្ងៃទី ១៤-៨-២០០៦ របស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តព្រៃវែង បានសម្រេចចោទប្រកាន់លើឈ្មោះ [redacted] រិន , [redacted] ប៉ោង និង [redacted] ពេជ ពីបទប្លន់មានអាវុធ ប្រព្រឹត្តនៅភូមិគកធំ ឃុំព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី ០៥-០៤-២០០៦ តាមមាត្រា ០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៤-ជនជាប់ចោទបានឆ្លើយនៅពេលសវនាការតុលាការខេត្តថា ខ្លួនពុំបានប្រព្រឹត្តអំពើប្លន់ដូចការចោទប្រកាន់ទេ ពេលនោះខ្លួននៅធ្វើស្រែពុំបានទៅណាទេ។ ប៉ុន្តែចម្លើយជនជាប់ចោទនៅនគរបាលស្របគ្នានឹងចម្លើយជនរងគ្រោះឈ្មោះ [redacted] ចេង ដែលថាបានប្រព្រឹត្តអំពើប្លន់ នៅថ្ងៃទី ០៥-០៤-២០០៦ វេលាម៉ោង ៨.៤៥នាទីព្រឹក នៅចំណុចភូមិគកធំ ឃុំព្រៃស្រឡិត បានម៉ូតូ១គ្រឿង សេ ១១០ ពណ៌ខ្មៅ និងខ្សែករមាសមួយខ្សែរបស់ជនរងគ្រោះលក់ចែកលុយគ្នាបាន ៣០០ ០០០៛ ម្នាក់ៗ។ ចម្លើយនៅនគរបាលនេះអាចយកជាការបានដោយសារជាចម្លើយស្របគ្នានឹងចម្លើយជនរងគ្រោះ ចំណែកការដោះសារថា ពុំបានប្រព្រឹត្តនោះពុំមានភស្តុតាងដោះបន្ទុកទេ។ ឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] រិន ពីបទៈ ប្លន់ ដូចការចោទប្រកាន់ស្ថាពររបស់ព្រះរាជអាជ្ញា



Scanned with CamScanner

ព្រាក់ដមែន។

៥-ក្នុងអំពើប្លន់នេះជនជាប់ចោទ និងបក្ខពួកបានប្រើប្រាស់អាវុធខ្លី តែព្រះរាជអាជ្ញាពុំបាន ធ្វើការចោទប្រកាន់ទេ។ សាលាឧទ្ធរណ៍ពុំអាចផ្តន្ទាទោសលើជនជាប់ចោទរូបនេះពីបទៈប្រើប្រាស់អាវុធគ្មានច្បាប់ទេ។ សាលាឧទ្ធរណ៍គ្រាន់តែធ្វើការកត់សំគាល់ជូនមហាអយ្យការដើម្បីចាត់ការតាមច្បាប់តែប៉ុណ្ណោះ។

៦-ការយល់ឃើញ និងការសម្រេចសេចក្តីរបស់តុលាការខេត្តព្រៃវែង ក្នុងសាលក្រមព្រហ្មទណ្ឌលេខ ៦៥"ខ"ព្រ.ទ ចុះថ្ងៃទី ០៥-១២-២០០៦ មានភាពត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់។ សាលាឧទ្ធរណ៍ឯកភាពទាំងស្រុងលើការយល់ឃើញនិងការសម្រេចសេចក្តីដោយពុំចាំបាច់បញ្ជាក់ជាថ្មីឡើងវិញទេ។ សាលាឧទ្ធរណ៍ឧទ្ធរណ៍សម្រេចតម្កល់សាលក្រមនេះ ទុកជាបានការដដែល។

ហេតុដូច្នេះ

**<u>ទនិច្ឆ័យសេចក្ត</u>**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៥-១២-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] រិន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៥"ខ" ចុះថ្ងៃទី ០៥-១២-២០០៦ របស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការ។

៣-បន្តការឃុំខ្លួនលើឈ្មោះ [redacted] រិន តាមមាត្រា ៣៥៣ និង ៣៩៦ ក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-ដីកាចាប់ខ្លួនលើឈ្មោះ [redacted] ពេជ និង [redacted] ប៉ោង នៅតែបន្តមានអានុភាព។

៥-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២១-០៧-២០០៩ កំបាំងមុខគូក្តី ចំពោះមុខមេធាវីការពារក្តីឱ្យជនជាប់ចោទ។

បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

**សេចក្តនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

សាលាឧទ្ធរណ៍ថ្ងៃទី ២០ ខែ ០៣ ឆ្នាំ ២០១៥

| បានឃើញ | |
|---|---|
| **ប្រធានសាលាឧទ្ធរណ៍** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |



១៩៦